# សិក្ខាសាលា
## ស្តីពី
## ការលើកកំពស់កិច្ចសហការរវាងស្ថាប័នតុលាការ អយ្យការ និងពន្ធនាគារ និងកិច្ចការពារសិទ្ធិកុមារក្នុងនីតិវិធីនៅតុលាការ

រៀបចំដោយសាលាឧទ្ធរណ៍

ក្រោមការឧបត្ថម្ភពីការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងអង្គការយូនីសេហ្វ

*ថ្ងៃពុធ ទី៥ ដល់ថ្ងៃសុក្រទី៧ ខែកញ្ញា ឆ្នាំ២០១២*

សណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ

## សន្ទរកថាស្វាគមន៍

**ដោយលោក James Heenan តំណាងស្តីទីនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR-Cambodia)**

ខ្ញុំសូមសំដែងការគោរពចំពោះ៖

- **ឯកឧត្តម គង់ ស្រីម** អនុប្រធានតុលាការកំពូល ដែលឯកឧត្តមបានឯកភាពបើកកិច្ចប្រជុំដ៏សំខាន់នេះឡើង។
- **ឯកឧត្តម យូ ប៊ុនឡេង** ប្រធានសាលាឧទ្ធរណ៍ សំរាប់ការរៀបចំកិច្ចប្រជុំនេះ។
- **ឯកឧត្តម អ៊ុក សាវុធ** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។
- **ឯកឧត្តម គុយ ប៊ុនសន** អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ។
- **ឯកឧត្តម ស៊ុយ ម៉ុងលាង** អគ្គលេខា នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។
- **ឯកឧត្តម ហ៊ី សុភា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌។
- **ឯកឧត្តម ជីវ សុង ហាក់** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមស្វាគមន៍ចំពោះអ្នកចូលរួមទាំងអស់ដែលមកពីបណ្តាខេត្ត ក្រុង នានានៃព្រះរាជាណាចក្រកម្ពុជា។ នេះគឺជាមោទនភាពចំពោះការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយឧបត្ថម្ភគាំទ្រដល់សិក្ខាសាលានេះ ដែលរៀបចំឡើងដោយសាលាឧទ្ធរណ៍។

សិក្ខាសាលានេះ ផ្តោតជាសំខាន់លើដំណើរបណ្តឹងឧទ្ធរណ៍ ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជនជាប់ឃុំទាំងឡាយមានសិទ្ធិទទួលបានការកាត់ក្តីក្នុងរយៈពេលសមស្របដោយតុលាការគ្រប់ជាន់ថ្នាក់ ។ ហើយពួកគេពុំគួររង់ចាំបណ្តឹងឧទ្ធរណ៍ដោយប្រើរយៈពេលយូរឡើយ។ នៅពេលជាមួយគ្នានេះ មានចំនួនជនជាប់ឃុំកើនឡើង១៥០០០នាក់ទូទាំងប្រទេស នេះសអោយឃើញថាប្រទេសកម្ពុជាកំពុងជួបប្រទះវិបត្តិណែនចង្អៀតក្នុងពន្ធនាគារ។ ដូចនេះហើយបានជាការិយាល័យយើងខ្ញុំមានឆន្ទៈសកម្មក្នុងគំរោងពង្រីកពង្រឹងសមត្ថភាព សាលាឧទ្ធរណ៍ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ អស់រយៈពេលច្រើនឆ្នាំហើយដែលយើង មានកង្វល់អំពីករណីឃុំលើសរយៈពេលកំណត់ដោយច្បាប់ ព្រោះថាមានជនជាប់ចោទ ជាច្រើនទាំងទណ្ឌិត និងពិរុទ្ធជនបាននឹងកំពុងរង់ចាំបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេលយូរ។

ជាលទ្ធផលផ្ទាល់ពីជំនួបរបស់ក្រុមអ្នកផ្តល់ជំនួយ ដែលការិយាល័យ OHCHR បានរៀបចំក្នុងឆ្នាំ ២០១០ យើងបានជួយស្វែងរកថវិកាដើម្បីសាងសង់បន្ទប់តុលាការ និងកន្លែងធ្វើការបន្ថែម ដើម្បីអោយសាលាឧទ្ធរណ៍មានលទ្ធភាពបើកសវនាការឧទ្ធរណ៍បានទាន់ពេលវេលា។ ការិយាល័យយើងខ្ញុំក៏បានបំពាក់គ្រឿងបរិក្ខារសំរាប់អគារថ្មីផងដែរ។ កិច្ចសហការរវាងការិយាល័យយើងខ្ញុំ និងសាលាឧទ្ធរណ៍កំពុងប្រព្រឹត្តទៅជាប្រក្រតី។ មន្ត្រីរបស់ការិយាល័យយើងខ្ញុំបាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនិងសាលាឧទ្ធរណ៍ ដើម្បីធ្វើបច្ចុប្បន្នភាពលើជំរឿនបណ្តឹងឧទ្ធរណ៍ដែលបានធ្វើកាលពីឆ្នាំមុនដើម្បីកំណត់ករណី អាទិភាពបើកសវនាការឧទ្ធរណ៍ រួមមានករណីដែលពិរុទ្ធជនរង់ចាំរយៈពេលយូរ។

យើងខ្ញុំសប្បាយរីករាយដោយបានកត់សំគាល់ឃើញការរីកចំរើននៅសាលាឧទ្ធរណ៍ក្នុងបញ្ហាដែលបានលើកឡើងនេះ។ ក្នុងរយៈកាលពីរ បីឆ្នាំកន្លងមកនេះ ការកកស្ទះករណីបណ្តឹងឧទ្ធរណ៍បានបញ្ចប់ការកើនឡើងគួរអោយកត់សំគាល់។ វិធានការថ្មីៗបាននឹងកំពុងដាក់ចុះដើម្បីធ្វើអោយការគ្រប់គ្រងករណីប្រសើរឡើង រួមមាន៖ ការដាក់អោយប្រើប្រាស់នូវប្រព័ន្ធទិន្នន័យថ្មី។ យើងសង្ឃឹមថា វិធានការ

ស្រដៀងគ្នានេះនឹងត្រូវបានរៀបចំនៅសាលាដំបូងរាជធានី ខេត្ត ក្រុងទូទាំងប្រទេសផងដែរ។ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់**ឯកឧត្តម យូ ប៊ុនឡេង** ប្រធានសាលាឧទ្ធរណ៍ សំរាប់កាដឹកនាំរបស់ឯកឧត្តមក្នុងវិស័យនេះ និងសំរាប់កិច្ចសហប្រតិបត្តិការដែលបានផ្តល់អោយការិយាល័យ OHCHR រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។

កិច្ចប្រជុំថ្ងៃនេះ មានសារៈសំខាន់ខ្លាំងណាស់ ហើយជាផ្នែកមួយដើម្បីកែលំអរដំណើរការប្រព័ន្ធយុត្តិធម៌ ហើយជាពិសេសគឺកិច្ចសហប្រតិបត្តិការរវាងតុលាការ ព្រះរាជអាជ្ញា និងពន្ធនាគារ។

តាមដែលខ្ញុំដឹង កិច្ចប្រជុំនេះគឺមិនដែលកើតមានពីមុនមកទេ ព្រោះថាយើងមានការជួបជុំប្រធានពន្ធនាគារ ប្រធានតុលាការ និងអយ្យការទូទាំងប្រទេស ដើម្បីជជែកអំពីការបង្កើនកិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មានរវាងស្ថាប័នទាំងបី។ យើងក៏បានអញ្ជើញមេធាវីដែលធ្វើការការពារបណ្តឹងឧទ្ធរណ៍ ក៏ដូចជា អ្នកតំណាងមកពីក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ផងដែរ។

កិច្ចប្រជុំនេះផ្តល់នូវឱកាសដ៏ពិសិដ្ឋ ដើម្បីអោយអ្នកចូលរួមទាំងអស់កំណត់នូវបញ្ហាប្រឈមចំពោះមុខ ហើយស្វែងរកដំណោះស្រាយពាក់ព័ន្ធនឹងការកកស្ទះបណ្តឹងឧទ្ធរណ៍នេះ។ ដើម្បីធ្វើអោយប្រសើរឡើងដល់ប្រព័ន្ធយុត្តិធម៌ ទាមទារអោយមានកិច្ចខិតខំប្រឹងប្រែងរួមពីសំណាក់ដៃគូរពាក់ព័ន្ធដែលបានចូលរួមសិក្ខាសាលានេះ។ យើងដឹងហើយថា ឯកឧត្តម លោក លោកស្រី មានទំនួលខុសត្រូវរៀងៗខ្លួន ប៉ុន្តែវាមិនគ្រប់គ្រាន់ទេបើយើងគ្រាន់តែយកចិត្តទុកដាក់ចំពោះតែភារកិច្ចម្នាក់ៗ។ ឯកឧត្តម លោក លោកស្រី ប្រហែលជាចង់ពិចារណាផងដែរ អំពីវិធីធ្វើការអោយប្រសើរឡើងជាមួយដៃគូរពាក់ព័ន្ធក្នុងគោលបំណងធានាថាដំណើរការយុត្តិធម៌អាចប្រព្រឹត្តទៅដោយរលូន។ វាជាការសំខាន់ណាស់ដើម្បីចងចាំថា យើងគ្រប់គ្នាឆ្លើយតប និងទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក។

ចំណុចចាប់ផ្តើមដើម្បីធ្វើអោយដំណើរការយុត្តិធម៌ប្រសើរឡើង គឺចាប់ផ្តើមពីការគ្រប់គ្រងករណីបណ្តឹងនៅសាលាដំបូង។ ករណីសំណុំរឿង គួរត្រូវបានរៀបចំដោយមានរបៀប លំដាប់លំដោយ និងធ្វើបច្ចុប្បន្នភាពរាល់ពេល។ ក្រោយពេលប្រកាសសាលក្រម ឬសាលដីកា ចៅក្រមមានភារកិច្ចចេញ

សម្រង់សាលក្រម ឬសាលដីកាភ្លាមៗ ហើយចែករំលែកវាជាមួយអយ្យការ ពន្ធនាគារ និងសាលាឧទ្ធរណ៍។ ពិតណាស់ទាំងនេះជាការទទួលខុសត្រូវរបស់ចៅក្រម ប៉ុន្តែពន្ធនាគារ គួរតែស្វែងរកជនជាប់ឃុំទាំងឡាយដែលពុំមានសាលក្រមឬសាលដីកាស្ថាពរ ហើយព្រះរាជអាជ្ញា គួរតែស្នើសុំសម្រង់សាលក្រម ឬសាលដីកាដែលមិនមានឬបាត់បង់នោះ។

នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ ករណីសំណុំរឿង គួរត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍អោយបានឆាប់តាមដែលអាចធ្វើបាន ដើម្បីអោយតុលាការមានលទ្ធភាពចាត់ការលើបណ្តឹងទាន់ពេលវេលា។

កិច្ចសហប្រតិបត្តិការតម្រូវអោយមាន ការចែករំលែកព័ត៌មានរវាងដៃគូរពាក់ព័ន្ធទាំងអស់។ ដូចនេះហើយ ការរៀបចំអោយមានកិច្ចប្រជុំទៀងទាត់រវាងស្ថាប័នពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ ដែលតម្រូវដោយសារាចរណែនាំ លេខ១៣៦០ របស់ក្រសួងយុត្តិធម៌ គឺជាការចាំបាច់ខ្លាំងណាស់។

ព័ត៌មានគួរត្រូវបានចែករំលែកក្នុងក្របខណ្ឌសាលាដំបូង រវាង ចៅក្រមស៊ើបសួរ អយ្យការ និងចៅក្រមជំនុំជម្រះ។

ពេលណាដែលមានការផ្ទេរឬបញ្ជូន ជនជាប់ឃុំ ព័ត៌មានគួរត្រូវបានចែករំលែករវាងពន្ធនាគារពាក់ព័ន្ធ។ ការផ្ទេរ ឬបញ្ជូននេះ គួរត្រូវបានកត់ត្រានៅក្នុងសៀវភៅបញ្ជីគោលរវាងពន្ធនាគារ បញ្ជូន និងពន្ធនាគារទទួលយក ហើយជនជាប់ឃុំដែលត្រូវបានបញ្ជូននោះ ត្រូវមានឯកសារពាក់ព័ន្ធជាប់ជាមួយ។

យើងដឹងហើយថា បញ្ហាប្រឈមជាចំបងក្នុងប្រទេសកម្ពុជា គឺការធានាថា ជនជាប់ឃុំត្រូវមានវត្តមាននៅពេលណាដែលសំណុំរឿងរបស់គេត្រូវបានលើកមកធ្វើសវនាការ ជាពិសេសគឺ ដំណាក់ការបណ្តឹងឧទ្ធរណ៍។ យើងជឿថា វាជាកាតព្វកិច្ចដែលតម្រូវអោយរាល់ជនទាំងឡាយដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ នឹងទទួលបានសិទ្ធិកាត់ក្តីដោយចំពោះមុខ និងសិទ្ធិមានមេធាវីការពារក្តីផង។ នេះជាសិទ្ធិសំខាន់ ដែលការពារដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជា បានផ្តល់សច្ចាប័ន។

ដូច្នេះខ្ញុំសង្ឃឹមថា ឯកឧត្តម លោក លោកស្រី និងជជែកគ្នារកដំណោះស្រាយ ដើម្បីធានាអោយមានការគោរពសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌។

នៅថ្ងៃទី៣ សិក្ខាសាលានេះនឹងត្រូវបានរៀបចំដោយសហការីយើងនៅមូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ (UNICEF) ដែលនឹងផ្តោតលើបញ្ហាយុត្តិធម៌កុមារ រួមទាំងការធានាថាការដកហូតសិទ្ធិសេរីភាពរបស់កុមារ គឺជាវិធានការចុងក្រោយ មិនមែនវិធានការដំបូងទេ។ ដូច្នេះ ឯកឧត្តម លោក លោកស្រី នឹងផ្តោតពិភាក្សាអំពីទោសជំនួសការឃុំឃាំងសំរាប់ កុមារនៅមុន អំឡុងពេល និងក្រោយពេលជំនុំជម្រះ។ ដូចដែលឯកឧត្តម លោក លោកស្រីបានជ្រាបហើយថា ប្រទេសកម្ពុជាជារដ្ឋហត្ថលេខី នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងជាប់កាតព្វកិច្ចក្នុងការការពារកុមារពីអំពើរំលោភបំពានគ្រប់ទម្រង់ទាំងអស់ ដែលបញ្ហានេះត្រូវបានចាត់ទុកថាជាបញ្ហាអាទិភាពមួយ។

ឯកឧត្តម លោក លោកស្រី នឹងធ្វើការ ដោយតាមរយៈជីវភាពប្រចាំថ្ងៃ គោលបំណងស្វែងរកដំណោះស្រាយក្នុងការអនុវត្តជាក់ស្តែង ដើម្បីអោយកុមារមានសុវត្ថិភាពពីអំពីហិង្សា និងគោរពនូវការធានាតាមផ្លូវច្បាប់សំរាប់កុមារអំឡុងនីតិវិធីយុត្តិធម៌។

ខ្ញុំដឹងថា ឯកឧត្តម លោក លោកស្រីមួយចំនួនបានធ្វើដំណើរ ពីបណ្តាខេត្តឆ្ងាយមកចូលរួមសិក្ខាសាលានេះដោយលះបង់ការងារដ៏សំខាន់មួយចំនួន។ ខ្ញុំជឿដែរថា នេះគឺជារសនិយមនៃឆន្ទៈរបស់ឯកឧត្តម លោក លោកស្រី ដើម្បីធ្វើអោយប្រព័ន្ធយុត្តិធម៌កម្ពុជាប្រសើរឡើង។

យើងខ្ញុំមានក្តីសង្ឃឹមយ៉ាងខ្ពស់ ចំពោះសិក្ខាសាលានេះ ហើយខ្ញុំជឿជាក់ថា ឯកឧត្តម លោក លោកស្រី នឹងចូលរួមចែករំលែកយ៉ាងសកម្មនូវបទពិសោធន៍ និងដំណោះស្រាយល្អៗ រវាងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។

ខ្ញុំសូមជូនពរអោយអង្គសិក្ខាសាលានេះប្រព្រឹត្តទៅដោយជោគជ័យ និងសង្ឃឹមទទួលបាននូវអនុសាសន៍ល្អៗពី ឯកឧត្តម លោក លោកស្រីនារសៀលថ្ងៃស្អែក។

សូមអរគុណ!